**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

លេខ:...១១១...នា-សផក

ថ្ងៃសុក្រ ១៣ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី...២៤...ខែ.....វិច្ឆិកា.....ឆ្នាំ២០២៣

**<u>សូមគោរពជូន</u>**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**<u>កម្មវត្ថុ</u>** : សំណើសុំការសម្រេចលើផែនការយុទ្ធសាស្ត្រនិងផែនការតាមដានអនុសាសន៍សវនកម្មផ្ទៃក្នុង បីឆ្នាំរំកិល២០២៤-២០២៦

**<u>យោង</u>**:
- ព្រះរាជក្រមលេខ នស/រកម/ ០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- អនុក្រឹត្យលេខ៤០ អនក្រ/បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- អនុក្រឹត្យលេខ៧១ អនក្រ/បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ប្រកាសលេខ៧០ ប្រក/បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការតាមដានអនុសាសន៍សវនកម្មផ្ទៃក្នុងបីឆ្នាំរំកិល២០២៤-២០២៦ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រួចជាស្ថាពរ សម្រាប់អនុវត្តការងារសវនកម្មបីឆ្នាំរំកិល២០២៤-២០២៦ ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពពីខ្ញុំបាទ ។

**ប្រធាននាយកដ្ឋាន**

**យួន_សុជាតិ**